# វេទិកាយុវជនកម្ពុជា

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី លទ្ធផលនៃកិច្ចពិគ្រោះយោបល់
## លើបញ្ហាប្រឈម ក្តីកង្វល់ និងអនុសាសន៍របស់យុវជន
## វេទិកាយុវជនកម្ពុជាលើកទី២ និងការប្រារព្ធទិវាយុវជនអន្តរជាតិ ឆ្នាំ២០២៤
## ក្រោមមូលបទ
## “ការពង្រឹងសមត្ថភាព និងសិទ្ធិអំណាចយុវជន
## ឆ្ពោះទៅរកយុត្តិធម៌សង្គមល្អប្រសើរ”

*រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤*

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៤ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១២ស្ថាប័ន បានសហការរៀបចំវេទិកាយុវជនកម្ពុជាលើកទី២ និងប្រារព្ធទិវាយុវជនអន្តរជាតិឆ្នាំ២០២៤ ក្រោមមូលបទ “**ការពង្រឹងសមត្ថភាព និងសិទ្ធិអំណាចយុវជន ឆ្ពោះទៅរកយុត្តិធម៌សង្គមល្អប្រសើរ**” ជាមួយនឹងវត្តមានអ្នកចូលរួមសរុប **៣០០**នាក់ ក្នុងនោះមានស្ត្រីចំនួន **១៥៧នាក់** ។

វេទិកាយុវជនកម្ពុជា និងការប្រារព្ធទិវាដ៏មានសារៈសំខាន់សម្រាប់យុវជនកម្ពុជានេះ រៀបចំឡើងដោយមានកិច្ចពិគ្រោះយោបល់ជាមួយអ្នកជំនាញ សិស្ស-និស្សិត ព្រះសង្ឃ សកម្មជនកិច្ចការសង្គម យុវជនអ្នកការពារព្រៃឈើ អ្នកការពារសិទ្ធិមនុស្សវ័យក្មេង តំណាងយុវជនមកពីសហគមន៍មូលដ្ឋាន យុវជនជនជាតិដើមភាគតិច ក្រុមយុវជនសហគ្រិនវ័យក្មេង យុវជនក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងយុវជនមកពីមជ្ឈដ្ឋានចម្រុះផ្សេងៗទៀត។ នៅវេទិកានោះ ក៏មានរៀបចំជាសិក្ខាសាលាចំនួន៤ ដូចជា ១).ការលើកកម្ពស់សេរីភាពមូលដ្ឋាន និងយុត្តិធម៌សង្គម ២). ការលើកកម្ពស់សិទ្ធិបរិស្ថាន និងកិច្ចការពារធនធានធម្មជាតិ ៣). យុវជន និងអក្ខរកម្មឌីជីថលក្នុងការទទួលព័ត៌មាន និង ៤). ទស្សនៈយុវជនចំពោះអំពើពុករលួយ៖ វឌ្ឍនភាព បញ្ហា និងមាគ៌ាឆ្ពោះទៅរកការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា ។

កិច្ចពិគ្រោះយោបល់លើប្រធានបទទាំងនោះ បានរកឃើញបញ្ហាប្រឈមរបស់យុវជន ដែលត្រូវចូលរួមដោះស្រាយពីគ្រប់ភាគី និងផ្តល់ជាអនុសាសន៍ ដូចមានបង្ហាញតាមប្រធានបទនីមួយៗខាងក្រោម៖

## I. ការលើកកម្ពស់សេរីភាពមូលដ្ឋាន និងយុត្តិធម៌សង្គម

សេរីភាពមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា នៅមិនទាន់មានភាពល្អប្រសើរនៅឡើយ ។ យោងតាមរបាយការណ៍ស្តីពី សេរីភាពមូលដ្ឋានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ឆ្នាំ២០២៣ បានបង្ហាញថាមានហេតុការណ៍ ចំនួន ៧១៤ ដែលប៉ះពាល់ដល់សេរីភាពសមាគម (៣៤៤ ហេតុការណ៍) សេរីភាពការជួបប្រជុំ (១៣៤ ហេតុការណ៍) និងសេរីភាពការបញ្ចេញមតិ (២៣៨ ហេតុការណ៍) ពាក់ព័ន្ធនឹងការរឹតត្បិតនិងរំលោភបំពាន ។

បន្ថែមពីនេះ ការយាយីតាមប្រព័ន្ធតុលាការចំពោះអ្នកធ្វើការផ្នែកសិទ្ធិមនុស្ស អ្នកការពារបរិស្ថាន និងសកម្មជនកិច្ចការសង្គមមួយចំនួនរួមមានករណីលោក ស៊ឹង សែនករុណា លោក កើត សារ៉ាយ លោក ស្រ៊ុន ស្រ៊ន យុវជនចលនានៃមាតាធម្មជាតិ ជាឧទាហរណ៍នៃការរារាំងដល់ភាពសកម្មរបស់យុវជន ។ ស្រដៀងគ្នានេះ កំណើននៃការចាប់ខ្លួនសមាជិកគណៈបក្សជំទាស់ សកម្មជនការងារសង្គម រួមទាំងសមាជិកសហជីព ក្រោមបទល្មើសព្រហ្មទណ្ឌដែលករណីទាំងនេះកាន់តែបង្កការខ្លាចរអាខ្លាំងឡើងៗ ក្នុងចំណោមប្រជាពលរដ្ឋនិងយុវជន។ បញ្ហាទាំងនេះបណ្តាលឱ្យពលរដ្ឋ ជាពិសេសយុវជន មិនមានភាពក្លាហានគ្រប់គ្រាន់ក្នុងការជជែកអំពីបញ្ហានយោបាយ និងអំពើអយុត្តិធម៌សង្គម ដោយពួកគេចាត់ទុកថា នយោបាយជារឿងគ្រោះថ្នាក់ ។ ជាងនេះទៅទៀត កត្តាចំណេះដឹងក៏ជាមូលហេតុរារាំងដល់ការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍផងដែរ ។

អង្គសិក្ខាសាលានេះបានកត់សម្គាល់បន្ថែមថា ប្រជាពលរដ្ឋ និងយុវជនមិនទាន់មានចំណេះដឹងពេញលេញអំពីលទ្ធិប្រជាធិបតេយ្យ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ខ្លួននៅឡើយទេ ។ យោងតាមទិន្នន័យសិក្សាស្រាវជ្រាវរបស់អង្គការតម្លាភាពកម្ពុជាឆ្នាំ២០២២ បង្ហាញថា នៅក្នុងចំណោមយុវជន ១៦០០នាក់ ដែលចូលរួមផ្តល់បទសម្ភាសន៍ មានយុវជនរហូតដល់ ៨២% គឺមិនចាប់អារម្មណ៍ពីនយោបាយឡើយ ។ ដោយឡែកតួនាទីរបស់សារព័ត៌មានឯករាជ្យក៏មានសារៈសំខាន់ផងដែរក្នុងការផ្តល់ព័ត៌មាន និងជំរុញការចូលរួមរបស់យុវជន ។ សិក្ខាសាលាបានកត់សម្គាល់បន្ថែមថា ពលរដ្ឋ និងយុវជនពុំទាន់ទទួលបានព័ត៌មានពិតពីសង្គមរបស់ខ្លួនគ្រប់គ្រាន់ឡើយ ដែលកត្តាទាំងនេះបានរារាំងដល់ការបញ្ចេញមតិ ការសម្រេចចិត្ត និងការចូលរួមរបស់ពួកគេផងដែរ ។ នៅក្នុងសិក្ខាសាលានេះ យុវជនដែលបានចូលរួមវេទិកាយុវជនកម្ពុជាលើកទី២ និងការប្រារព្ធទិវាយុវជនអន្តរជាតិឆ្នាំ២០២៤ បានផ្តល់ ***អនុសាសន៍*** ដល់ភាគីពាក់ព័ន្ធដូចខាងក្រោម៖

១). រាជរដ្ឋាភិបាលគួរផ្តល់ឱកាសដល់យុវជនចូលរួមក្នុងកិច្ចការសង្គមដោយគ្មានការភ័យខ្លាច បើកលំហសេរីភាពឱ្យយុវជនអាចសម្តែងមតិដោយសេរី និងបង្កលក្ខណៈងាយស្រួលសម្រាប់ការជជែកពិភាក្សាជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្ត ។

២). រាជរដ្ឋាភិបាលគួរពន្លឿននីតិវិធី និងស្នើទៅកាន់រដ្ឋសភា ដើម្បីពិភាក្សាអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានឱ្យបានលឿនបំផុត ។

៣). រាជរដ្ឋាភិបាលគួរបង្កើនកម្មវិធីអភិវឌ្ឍន៍សហគមន៍ ពង្រឹងគុណភាពអប់រំ និងចំនួនអន្តេវាសិកដ្ឋាន និងកម្មវិធីផ្តល់អាហាររូបករណ៍បន្ថែមទៀតសម្រាប់យុវជន សិស្សានុសិស្ស នៅតំបន់ដាច់ស្រយាល និងតំបន់ភាគឦសាន្តនៅក្នុងប្រទេសកម្ពុជា ។

៤). អង្គការសង្គមស៊ីវិល និងអ្នកជំនាញផ្នែកចិត្តសាស្ត្រ គួរបង្កើតកម្មវិធីអប់រំសុខភាពផ្លូវចិត្ត ដល់បុគ្គលិកសហគមន៍រងគ្រោះពីគម្រោងអភិវឌ្ឍន៍ អ្នកការពារសិទ្ធិមនុស្ស និងយុវជនសកម្ម ដែលរងសម្ពាធផ្លូវចិត្តដោយសារកត្តាសង្គម និងការរឹតត្បិតការអនុវត្តលំហសេរីភាព ។

៥). ក្រសួងអប់រំ យុវជន និងកីឡា គួរបង្កើនចំនួនម៉ោង និងវគ្គសិក្សាបន្ថែម ជាពិសេសលើការស្វែងយល់អំពីសិទ្ធិមនុស្សជាមូលដ្ឋានរួមមានសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ ការពិភាក្សាអំពីកិច្ចការសង្គមនយោបាយ សិទ្ធិមនុស្ស និងសេរីភាពនៃការជ្រើសរើសប្រធានបទសិក្សាស្រាវជ្រាវគួរមានការបើកចំហឱ្យបានទូលំទូលាយ ។

## II. លើកកម្ពស់សិទ្ធិបរិស្ថាន និងកិច្ចការពារធនធានធម្មជាតិ

ការបន្តបាត់បង់ព្រៃឈើ និងធនធានធម្មជាតិលឿនយ៉ាងគំហុក គឺជាក្តីបារម្ភយ៉ាងខ្លាំងមកលើសេដ្ឋកិច្ច និងសង្គមកម្ពុជា ដ្បិតព្រៃឈើបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការផលិតអុកស៊ីសែន និងស្រូបយកឧស្ម័នកាបូនិកដែលកកើតឡើងដោយសកម្មភាពរបស់មនុស្ស ដើម្បីធានានូវលំនឹងនៃអាកាសធាតុ ។ ទោះបីជារដ្ឋាភិបាលបានដាក់ចេញនូវយន្តការ យុទ្ធសាស្ត្រ និងវិធានការ ដើម្បីទប់ស្កាត់និងស្តារព្រៃឈើឡើងវិញក៏ដោយ ។ តួយ៉ាងដូចជាកម្មវិធីព្រៃឈើជាតិ ឆ្នាំ២០១០-២០២៩ យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ក្រមបរិស្ថាននិងធនធានធម្មជាតិក៏ដោយក៏ព្រៃឈើនៅតាមតំបន់ការពារធម្មជាតិ នៅទទួលរងការកាប់បំផ្លាញ ហើយរដ្ឋាភិបាលនៅតែបន្តសម្រេចចិត្ត កាត់ដីតំបន់ការពារធម្មជាតិប្រគល់ឱ្យវិស័យឯកជនដើម្បីអភិវឌ្ឍន៍ផងដែរ ។

យោងតាមរបាយការណ៍ស៊ើបអង្កេតរបស់កាសែតអាម៉េរិកម៉ុងហ្គាបេ កម្ពុជាបានបាត់បង់ព្រៃឈើទំហំ ១សែន ២ម៉ឺនហិកតា ឬស្មើនឹងទំហំនៃទីក្រុងឡូសអ៊ែនជីឡេសសហរដ្ឋអាមេរិក ក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ។ ចំណែកឯសិទ្ធិបរិស្ថានដែលបានធានាដោយមាត្រា៣១ មាត្រា៣៥ មាត្រា៤១ នៃច្បាប់រដ្ឋធម្មនុញ្ញ ព្រមទាំងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើវិញ ត្រូវបានគេមើលឃើញថា មានលក្ខណៈរួមតូច និងកាន់តែចង្អៀត ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៩ មក សហគមន៍មូលដ្ឋាន សមាគម អង្គការមិនមែនរដ្ឋាភិបាល និងយុវជន មិនត្រូវបានអនុញ្ញាតឱ្យចុះកម្មសិក្សា ចូលរួមល្បាត និងការពារព្រៃឈើនៅក្នុងតំបន់ដែនជម្រកសត្វព្រៃព្រៃឡង់ និងដែនជម្រកសត្វព្រៃព្រះករាបន្តទៀតឡើយ ។ ចំណែកឯ រាល់ទិន្នន័យដែលទាក់ទងនឹងបទល្មើសព្រៃឈើដែលបានស៊ើបអង្កេត និងប្រមូលដោយសហគមន៍មូលដ្ឋាន និងសមាគម អង្គការមិនមែនរដ្ឋាភិបាល តែងតែត្រូវបានក្រសួងបរិស្ថានបដិសេធ ប្រានចោល និងមិនទទួលស្គាល់ ទោះបីមានភ្ជាប់ជាមួយភស្តុតាងរឹងមាំយ៉ាងណាក៏ដោយ ។

ការប្រែប្រួលអាកាសធាតុ ក៏ជាបញ្ហាសំខាន់ដែលរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធត្រូវតែគិត និងត្រៀមយន្តការក្នុងការឆ្លើយតប ។ ថ្វីដ្បិតធនាគារពិភពលោកបានចាត់ទុកប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេស ដែលងាយរងគ្រោះដោយគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍ ដោយទទួលបានចំណាត់ថ្នាក់ ១៤០/១៨១ បណ្តាលមកពី

ទឹកជំនន់ និងគ្រោះរាំងស្ងួតតាមរដូវកាល ។ ចំណែកឯសមត្ថភាពបន្សាំនៅមានលក្ខណៈខ្សោយ និងមានហេដ្ឋារចនាសម្ព័ន្ធមិនល្អផងដែរ ។ នៅក្នុងសិក្ខាសាលានេះ យុវជនដែលបានចូលរួមវេទិកាយុវជនកម្ពុជាលើកទី២ និងការប្រារព្ធទិវាយុវជនអន្តរជាតិឆ្នាំ២០២៤ បានផ្តល់***អនុសាសន៍***ដល់ភាគីពាក់ព័ន្ធដូចខាងក្រោម៖

១). រាជរដ្ឋាភិបាល គួរបង្កើនការលើកទឹកចិត្តដល់យុវជនឱ្យចូលរួមកិច្ចការពារធនធានធម្មជាតិ បរិស្ថាន និងទ្រព្យសម្បត្តិសាធារណៈ ដើម្បីធានាបានភាពសកម្មក្នុងការចូលរួមការពារ អភិរក្ស និងការអនុវត្តសិទ្ធិបានពេញលេញ ។

២). បង្កើតការងារ និងបណ្តុះបណ្តាលប្រជាពលរដ្ឋក្រីក្រនៅជុំវិញតំបន់ការពារធម្មជាតិ លើកកម្ពស់ជីវភាព ដើម្បីឱ្យពួកគាត់បោះបង់មុខរបរកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់ និងជំរុញការចងក្រងសហគមន៍ផលិតផលអនុផលព្រៃឈើសម្រាប់សហគមន៍មូលដ្ឋាន ដែលរស់នៅជុំវិញតំបន់ការពារធម្មជាតិ ។

៣). បង្កើនការផ្សព្វផ្សាយអំពីក្រមបរិស្ថាន និងធនធានធម្មជាតិ និងអភិរក្សធនធានធម្មជាតិទៅកាន់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ និងផ្តល់ការបំប៉នដល់មន្ត្រីឧទ្យានុរក្សលើការស្វែងយល់ពីក្រមនេះឱ្យមានប្រសិទ្ធិភាព ដើម្បីបញ្ចៀសការយល់ផ្ទុយគ្នាលើការអនុវត្តការងារ រវាងមន្ត្រីបច្ចេកទេស និងសហគមន៍មូលដ្ឋានដែលជាអ្នកអនុវត្តសិទ្ធិ ។

៤). បង្កើនការត្រួតពិនិត្យ តាមដាន វាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់របស់អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងអនុវត្តច្បាប់ដោយគ្មានការលើកលែងចំពោះបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសធនធានធម្មជាតិ ឬប្រព្រឹត្តអំពើពុករលួយ ធ្វេសប្រហែសក្នុងការបំពេញមុខងារក្នុងការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ ។

៥). ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ គួរបង្កើនកញ្ចប់ថវិកាគាំទ្រដល់សហគមន៍មូលដ្ឋាន យុវជន និងប្រជាពលរដ្ឋ ដែលចាប់អារម្មណ៍ចង់ចូលរួមការពារធនធានធម្មជាតិ ។ រដ្ឋបាលឃុំ សង្កាត់ អាចដាក់បញ្ចប់ថវិកាឃុំជាប្រចាំឆ្នាំ ដើម្បីគាំទ្រដល់សហគមន៍មូលដ្ឋាន ។

## III. យុវជន និងអក្ខរកម្មឌីជីថលក្នុងការទទួលបានព័ត៌មាន

ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា បានធ្វើឱ្យមានកំណើនព័ត៌មានពិត និងព័ត៌មានមិនពិត ការប្រើប្រាស់ និងបញ្ចេញមតិមិនសមរម្យ ការឃ្លាំមើល ការរំលោភលើឯកជនភាព និងការរើសអើងយេនឌ័រជាដើម ។ មូលហេតុទាំងអស់នេះធ្វើឱ្យអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានភាពចាំបាច់ក្នុងការផ្តល់ជូនបុគ្គលម្នាក់ៗ នូវចំណេះដឹង ជំនាញ អាកប្បកិរិយា និងតម្លៃនានា ដែលមិនត្រឹមតែជួយការពារខ្លួនពីហានិភ័យប៉ុណ្ណោះទេ ថែមទាំងផ្តល់សិទ្ធិអំណាចដល់ពួកគេអាចទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាបានផងដែរ ។

យោងតាម ក្របខណ្ឌគោលនយោបាយធ្វើបរិវត្តកម្មឌីជីថល សេដ្ឋកិច្ច និងសង្គម គិតត្រឹមឆ្នាំ២០២០ នៅកម្ពុជាមានប្រជាជន ៣២% អាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថលកម្រិតមូលដ្ឋាន ៥% មានជំនាញកម្រិតមធ្យម និង ១% មានជំនាញកម្រិតខ្ពស់ ។ យោងតាមនិយ័តករទូរគមនាគមន៍កម្ពុជា គិតត្រឹមខែកញ្ញាឆ្នាំ២០២៤ មានចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចំនួន ១៩លាន ៥សែន និងអ្នកប្រើប្រាស់អ៊ីនធឺណេត មានប្រមាណចំនួន ១៨លាននាក់ ។

ការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យា បញ្ញាសប្បនិម្មិតបានបង្កើនជាការព្រួយបារម្ភយ៉ាងខ្លាំងដោយប្រទេសកម្ពុជាមិនទាន់មានច្បាប់ក្នុងការគ្រប់គ្រងនៅឡើយ ដើម្បីជំរុញការដោះស្រាយបញ្ហាប្រឈមសម្រាប់ការឈានទៅរកការកសាងប្រព័ន្ធអប់រំ និងសីលធម៌សង្គម មានភាពល្អប្រសើរ ។ នៅក្នុងសិក្ខាសាលានេះ យុវជនដែលបានចូលរួមវេទិកាយុវជនកម្ពុជាលើកទី២ និងការប្រារព្ធទិវាយុវជនអន្តរជាតិឆ្នាំ២០២៤ បានផ្តល់***អនុសាសន៍*** ដល់ភាគីពាក់ព័ន្ធដូចខាងក្រោម៖

១). ក្រសួង ស្ថាប័នពាក់ព័ន្ធគួរតែបង្កើតគោលនយោបាយក្នុងការពង្រឹងសមត្ថភាព និងការដាក់បញ្ចូលអក្ខរកម្មឌីជីថលទៅក្នុងកម្មវិធីសិក្សាប្រព័ន្ធអប់រំរបស់រដ្ឋ ឱ្យមានភាពទូលំទូលាយ ពង្រឹងសមត្ថភាពលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ដើម្បីបង្កបរិយាកាសងាយស្រួលក្នុងការប្រើប្រាស់ បង្កើត ប្រសិទ្ធភាព និងប្រសិទ្ធផលបន្ថែម ។

២). យុវជនខ្លួនឯងត្រូវខិតខំប្រឹងប្រែងតាមដានការវិវត្តថ្មីៗ នៃអក្ខរកម្មឌីជីថលដើម្បីដើរឱ្យទាន់បរិបទ និងបដិវត្តន៍ឧស្សាហកម្មបច្ចេកវិទ្យាជំនាន់ទី ៤.0 និងមើលឃើញពីភាពចាំបាច់សំខាន់ដោយដាក់បញ្ចូលអក្ខរកម្មឌីជីថលចូលក្នុងការរស់នៅនិងការប្រើប្រាស់ប្រចាំថ្ងៃ ។

## IV. ទស្សនៈយុវជនចំពោះអំពើពុករលួយ៖ វឌ្ឍនភាព បញ្ហា និងមាគ៌ាឆ្ពោះទៅរកការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា

អំពើពុករលួយនៅតែជាក្តីបារម្ភចម្បងសម្រាប់យុវជនកម្ពុជា បើទោះបីជាកម្ពុជាមាន ច្បាប់ស្តីពី ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយក៏ដោយ ។ បញ្ហាអំពើពុករលួយនៅតែកើតមាន បានធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង  ដែលជះឥទ្ធិពលអវិជ្ជមានសម្រាប់ការអភិវឌ្ឍសង្គមជាតិ និងការចូលរួមរបស់យុវជនកម្ពុជា ។ យោងទៅតាមទិន្នន័យ របស់អង្គការតម្លាភាពកម្ពុជា ប្រទេសកម្ពុជាមានពិន្ទុ២២ ក្នុងចំណោម ១០០ នៅក្នុង២០២៣ ដែលថយចុះ២ពិន្ទុ បើធៀបនឹងឆ្នាំ២០២២ និងជាប់ចំណាប់ថ្នាក់ទី១៥៨ នៅក្នុងចំណោម ១៨០ប្រទេស ។ ដោយមើលឃើញពីភាពចាំបាច់នៃការចូលរួម និងការទប់ស្កាត់ អំពើពុករលួយនៅកម្ពុជា នៅក្នុងសិក្ខាសាលានេះ យុវជនដែលបានចូលរួមវេទិកាយុវជនកម្ពុជាលើកទី២ និងការប្រារព្ធទិវាយុវជនអន្តរជាតិឆ្នាំ ២០២៤ បានផ្តល់***អនុសាសន៍*** ដល់ភាគីពាក់ព័ន្ធដូចខាងក្រោម៖

១). រាជរដ្ឋាភិបាលកម្ពុជាត្រូវមានមានឆន្ទៈខ្លាំងក្លា និងចាត់ទុកបញ្ហានេះជាបញ្ហាអាទិភាព ដោយពង្រឹងអភិបាលកិច្ចល្អ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បន្ថែមប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ មានចំណាត់ការតឹងរ៉ឹងទៅលើអំពើពុករលួយ និងការអនុវត្តច្បាប់ឱ្យបានពេញលេញ ។

២). រាជរដ្ឋាភិបាលគួរពន្លឿនការអនុម័តច្បាប់ការការពារបុគ្គលរាយការណ៍ និងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដើម្បីរក្សាឱ្យបាននូវតម្លាភាព និងគណនេយ្យភាព ។ រាជរដ្ឋាភិបាលត្រូវពិនិត្យ ជំរុញធ្វើឱ្យដំណើរការឡើងវិញនូវប្រអប់គណនេយ្យភាពនៅតាមសហគមន៍ និងបង្កលក្ខណៈងាយស្រួលក្នុងការអនុវត្តបណ្តឹងចំពោះសកម្មភាពនៃការប្រព្រឹត្តអំពើពុករលួយ ។

៣). យុវជនកម្ពុជា ត្រូវចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់ រាយការណ៍ ការមិនប្រព្រឹត្ត និងចូលរួមសកម្មភាពផ្សព្វផ្សាយអំពី ភាពសកម្មនៃការទប់ស្កាត់អំពើពុករលួយនៅក្នុងសង្គម ។ យុវជនគប្បីចាប់ផ្តើមពីភាពស្អាតស្អំរបស់ខ្លួន ដោយមិនពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើពុករលួយ ត្រូវហ៊ានសម្តែងមតិថ្កោលទោសទៅលើអំពើពុករលួយ និងអ្នកប្រព្រឹត្តអំពើពុករលួយគ្រប់ទម្រង់ ។

បញ្ហាប្រឈមពាក់ព័ន្ធបរិយាសសង្គម នយោបាយ ការគោរពសិទ្ធិមនុស្ស អំពើពុករលួយ និងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យព័ត៌មានវិទ្យាឌីជីថល នៅតែជាកត្តាជះឥទ្ធិពលយ៉ាងខ្លាំងដល់យុវជនកម្ពុជាទាំងឥរិយាបថ ផ្នត់គំនិត ផ្លូវចិត្ត និងសុវត្ថិភាព ដែលបានក្លាយជាកត្តារាំងស្ទះដល់ភាពសកម្មនៃការចូលរួមកិច្ចការសង្គម នយោបាយ និងការសម្រេចចិត្តចំពោះជោគវាសនារបស់ពួកគេ ។ ខណៈប្រទេសកម្ពុជា ជាប្រទេសដែលមានយុវជន និងប្រជាជនវ័យក្មេងចំនួនភាគច្រើនធៀបនឹងប្រជាជនសរុប យើងទាំងអស់គ្នាសង្ឃឹមថា អនុសាសន៍ខាងលើនឹងត្រូវបានរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធទទួលយកពិចារណា ដើម្បីឆ្លើយតបទៅនឹងសេចក្តីកង្វល់បញ្ហាប្រឈម ដែលបានលើកឡើងនៅក្នុងវេទិកាយុវជនកម្ពុជា និងការប្រារព្ធទិវាយុវជនអន្តរជាតិ ឆ្នាំ២០២៤នេះ ។ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធគួរបង្កលក្ខណៈ និងលក្ខខណ្ឌល្អប្រសើរដល់យុវជន ឱ្យបានចូលរួមយ៉ាងសកម្មទាំងកិច្ចការ សង្គម នយោបាយ សេដ្ឋកិច្ច វប្បធម៌ និងការអនុវត្តសិទ្ធិពលរដ្ឋឱ្យបានពេញលេញ ទើបពួកគេមានកាលានុវត្តភាព និងនាវានុវត្តគ្រប់គ្រាន់ ក្នុងការចូលរួមសកម្មភាពសង្គមជាតិបានល្អប្រសើរ ។ ការបើកលំហសេរីភាពពេញលេញ សម្រាប់យុវជន គឺធ្វើឱ្យពួកគេឆ្ពោះទៅរកការចូលរួមមួយដែលមានភាពសកម្ម ដើម្បីជំរុញវឌ្ឍនភាព និងបង្កើតបាន ភាពល្អប្រសើរនៃយុត្តិធម៌សង្គម ។ ផ្ទុយទៅវិញ ប្រសិនបើយុវជន ពុំទទួលបានលំហសេរីភាពពេញលេញ និងបរិយាកាសសង្គមមិនល្អប្រសើរនោះយុវជននឹងក្លាយជាកម្លាំងចលករបំពេញមហិច្ឆតារបស់អ្នកនយោបាយតែប៉ុណ្ណោះ ហើយសំឡេងរបស់ពួកគេនឹងនៅតែត្រូវបានបំបាត់ចោល ។

ដូចបានរៀបរាប់អំពីបញ្ហាប្រឈម ក្តីកង្វល់ និងអនុសាសន៍ខាងលើ យើងខ្ញុំទាំងអស់គ្នាដែលជាសមាគមអង្គការមិនមែនរដ្ឋាភិបាល និងក្រុមយុវជន មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថារាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នពាក់ព័ន្ធនឹងយកចិត្តទុកដាក់ក្នុងការទទួលយក និងដោះស្រាយឱ្យមានប្រសិទ្ធភាពជាទីបំផុត សម្រាប់លើកទឹកចិត្តដល់ការចូលរួមរបស់យុវជនឱ្យអស់ពីសក្តានុពល និងថាមពលក្នុងភាពជាពលរដ្ឋសកម្មសម្រាប់ប្រទេសកម្ពុជារបស់យើងទាំងអស់គ្នា ៕

*ព័ត៌មានបន្ថែម សូមទាក់ទង៖*

**លោក ហេង គឹមហុង** ប្រធានប្រតិបត្តិ នៃសមាគមបណ្ដាញយុវជនកម្ពុជា
តាមរយៈលេខទូរស័ព្ទ ០៩៦ ៧៨៨ ៨៣៦៨ / ០៩២ ៦៦៧ ៥៩៩

**កញ្ញា ប៉ាញ ចិន្តា** អនុប្រធានបរិស្ថាននៃអង្គការ ជេស្វីតសឺវីសកម្ពុជា
តាមរយៈលេខទូរស័ព្ទ ០១៥ ៥៨៥ ២១៤

**លោក សាន់ ម៉ាឡា** ប្រធានកម្មវិធី នៃអង្គការជាដៃគូរដើម្បីបរិស្ថាន និងការអភិវឌ្ឍ
តាមរយៈលេខទូរស័ព្ទ ០១៥ ៩៩៨ ៥៥៥

**លោក ចណ្ណា ម៉ុនណា** ប្រធានផ្នែកស្រាវជ្រាវ និងតស៊ូមតិ នៃសមាគមបណ្ដាញយុវជនកម្ពុជា
តាមរយៈលេខទូរស័ព្ទ ០៦៩ ៨២៩ ៥៨៣

**លោក ហឿម ម៉ុនហេង** អ្នកសម្របសម្រួលកម្មវិធី នៃវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា
តាមរយៈលេខទូរស័ព្ទ ០៦៩ ៦៣៨ ៣៣៩

**កញ្ញា សំរេច មេត្តា** មន្ត្រីកម្មវិធី នៃអង្គការតម្លាភាពកម្ពុជា
តាមរយៈលេខទូរស័ព្ទ ០៩៦ ៧៧៦ ៩៣៥១